**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ០៣ រោច ខែ ជេស្ឋ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីការចុះហត្ថលេខាលើកិច្ចសន្យាពាណិជ្ជកម្មសម្រាប់គម្រោងជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ រវាងក្រសួងពាណិជ្ជកម្ម ជាមួយក្រុមហ៊ុន CITIC Construction Co., Ltd

នាព្រឹកថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៩, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាពាណិជ្ជកម្ម ស្តីពីគម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ក្នុងក្របខ័ណ្ឌឥណទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន រវាងឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងលោក **Chen Xiaojia** ប្រធានក្រុមហ៊ុន **CITIC Construction Co., Ltd** ។

គម្រោងជំរុញផលិតកម្ម ស្រូវ និងការនាំចេញអង្ករនេះ ត្រូវបានរៀបចំឡើងក្នុងគោលដៅដើម្បីជួយដល់កសិករ ធុរជន និងក្រុមហ៊ុននាំចេញអង្ករ ព្រមទាំងរួមចំណែកគាំទ្រដល់យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើការជំរុញការនាំចេញអង្ករឱ្យបានយ៉ាងតិច ១ លានតោន ក្នុងមួយឆ្នាំ តាមរយៈការសាងសង់ឃ្លាំងស្តុក និងឡសម្ងួតនៅតាមទីតាំងយុទ្ធសាស្ត្រ និងការដាក់ឱ្យអនុវត្តយន្តការយកស្រូវ-អង្ករស្តុកក្នុងឃ្លាំងជាវត្ថុបញ្ចាំសម្រាប់ខ្ចីប្រាក់ពីធនាគារឯកជន ។ គម្រោងនេះ គឺដើម្បីទប់ស្កាត់កុំឱ្យឈ្មួញទុច្ចរិត អាចឆ្លៀតឱកាសបង្ខំថ្លៃស្រូវ ក៏ដូចជាដើម្បីជួយឱ្យកសិករទុកស្រូវបានយូរ អាចលក់ស្រូវបានតាមថ្លៃសមរម្យ និងមានលទ្ធភាពទទួលបានឥណទានពេលត្រូវការចាំបាច់ តាមរយៈការយកស្រូវស្តុកក្នុងឃ្លាំងជាវត្ថុបញ្ចាំ ។ គម្រោងនេះ មិនមានសេវាកិនស្រូវទេ ដើម្បីការពារកុំឱ្យមានការប្រកួតប្រជែងជាមួយរោងម៉ាស៊ីនកិនស្រូវក្នុងស្រុក ។

បន្ទាប់ពីគម្រោងនេះដាក់ឱ្យប្រតិបត្តិការ, កសិករ និងរោងម៉ាស៊ីនកិនស្រូវ នឹងមានឡសម្ងួត ឃ្លាំងស្តុក និងទុនបង្វិលបន្ថែម ព្រមទាំងជួយបន្ថយចំណាយ (ថ្លៃដើម) ចាប់ពីដំណាក់កាលប្រមូលផលដល់ដំណាក់កាលលក់អង្ករ ។

រយៈកិច្ចសន្យាពាណិជ្ជកម្មនេះ, ក្រុមហ៊ុន **CITIC Construction Co., Ltd** និងក្រុហ៊ុនហ្គ្រីនត្រេដ នឹងធ្វើការសាងសង់ឃ្លាំងស្តុកស្រូវ-អង្ករ ចំនួន ១២ កន្លែង (សមត្ថភាពស្តុកសរុប ៨២៧ ០០០ តោន) និងឡសម្ងួត ចំនួន ១០ កន្លែង (សមត្ថភាពសម្ងួតស្រូវបាន ១៣ ០០០ តោន ក្នុងមួយថ្ងៃ) នៅក្នុងខេត្តពោធិ៍សាត់ បាត់ដំបង តាកែវ បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ព្រៃវែង កណ្តាល កំពង់ស្ពឺ និងខេត្តព្រះសីហនុ ។

ជាមួយនឹងការអនុវត្តគម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ, រាជរដ្ឋាភិបាលសង្ឃឹមថា កម្ពុជានឹងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្កើនការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ និងលើកកម្ពស់កេរ្តិ៍ឈ្មោះអង្ករកម្ពុជា ។ ពិធីចុះហត្ថលេខានាពេលនេះ គឺគូសបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់លើវិស័យកសិកម្ម ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។